EMBASSY OF JAPAN
IN CAMBODIA

# PRESS RELEASE

No. 32PR-25/EoJ 9 October 2025

## Japan Provides US$183,588 for Procurement of Japanese Ambulances and Installation of Medical Equipment

The Government of Japan will provide US$183,588 in total for two recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE")*. The Grant Contracts were signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of two recipients respectively, to carry out the following projects.

1. 'The Project for the Procurement of Secondhand Ambulance in Phnom Penh City, Kandal and Preah Sihanouk provinces' (US$120,308)
Recipient: Police Department of Fire Prevention and Rescue, Ministry of Interior
The grant will be used to procure Japanese ambulances for Phnom Penh City, Kandal, and Sihanoukville Provinces. This project aims to improve emergency response in Cambodia's urban areas, where rapid development has led to frequent fire incidents due to unsafe buildings and complex wiring. Despite having medical staff at fire stations, the lack of ambulances delays life-saving efforts, sometimes resulting in fatalities. To address this, four ambulances will be provided to fire stations—two in Phnom Penh, one in Kandal province, and one in Preah Sihanouk province—enabling faster emergency response and care in the event of a fire. This initiative will benefit approximately 4.14 million residents by improving fire-related rescue operations and enhancing public safety.

2. 'The Project for the Installation of Medical Equipment at Borkeo Referral Hospital in Ratanakiri Province' (US$63,280)
Recipient: Borkeo Referral Hospital
This grant will be used to install a new X-ray machine, electrocardiograph (ECG), and generator at the Borkeo Referral Hospital. Since its X-ray machine broke down in 2021, patients requiring imaging must travel 30 km to the provincial hospital, incurring high transport costs and delays in diagnosis. Moreover, frequent power outages, especially during the rainy

season, further hinder treatment, as the general ward lacks a generator, forcing doctors to work with flashlights. Additionally, the hospital lacks an ECG, essential for early detection of heart conditions. By installing a new X-ray machine, ECG, and generator, the hospital will be able to provide faster and more accurate diagnoses, improving care for approximately 9,500 patients annually and reducing the financial burden on rural communities.

Japan's "KUSANONE" Projects started in Cambodia in 1991 in order to support Cambodia's reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and/or misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities. Since 1991, the Government of Japan has provided over US$72 million for mainly local authorities and non-governmental organizations to implement 706 KUSANONE projects throughout Cambodia.

---

*Embassy of Japan in Cambodia*
*Tel: 023-217-161*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 32PR-25/EoJ ថ្ងៃទី០៩ ខែតុលា ឆ្នាំ២០២៥

**ជប៉ុនផ្តល់ថវិកា ១៨៣,៥៥៨ ដុល្លារអាមេរិក**
**សម្រាប់លទ្ធកម្មរថយន្តពន្លត់អគ្គិភ័យជប៉ុន**
**និងការបំពាក់បរិក្ខារពេទ្យ**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន ១៨៣,៥៥៨ ដុល្លារអាមេរិក ដល់ស្ថាប័នទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណេ)។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង តំណាងស្ថាប័នទទួលជំនួយទាំងពីរ ដើម្បីអនុវត្តគម្រោងដូចតទៅ៖

**១. គម្រោងធ្វើលទ្ធកម្មរថយន្តសង្គ្រោះបន្ទាន់ដែលប្រើប្រាស់រួច ក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ (ថវិកាចំនួន ១២០,៣០៥ ដុល្លារអាមេរិក)**

*ស្ថាប័នទទួលជំនួយ៖ នាយកដ្ឋាននគរបាលបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ នៃក្រសួងមហាផ្ទៃ*

ជំនួយនេះនឹងត្រូវបានប្រើប្រាស់ដើម្បីធ្វើលទ្ធកម្មរថយន្តសង្គ្រោះរបស់ជប៉ុនសម្រាប់រាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ។ គម្រោងនេះមានគោលបំណងលើកកម្ពស់ការឆ្លើយតបបន្ទាន់នៅតំបន់ទីប្រជុំជន ក្នុងប្រទេសកម្ពុជា ដែលការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៅតំបន់ទីប្រជុំជនបាននាំមកនូវឧប្បត្តិហេតុអគ្គិភ័យជាញឹកញាប់ ដោយសារកត្តាអគារពុំមានសុវត្ថិភាព និងបណ្តាញខ្សែភ្លើងដ៏ស្មុគស្មាញ។ ទោះបីជាមានបុគ្គលិកសុខាភិបាលនៅស្ថានីយ៍ពន្លត់អគ្គិភ័យក៏ដោយ ការខ្វះខាតនូវរថយន្តសង្គ្រោះបន្ទាន់បានពន្យារកិច្ចខិតខំប្រឹងប្រែងជួយសង្គ្រោះជីវិត ដែលពេលខ្លះអាចបណ្តាលឱ្យមានអ្នកស្លាប់។ ដើម្បីដោះស្រាយបញ្ហានេះ រថយន្តសង្គ្រោះបន្ទាន់ចំនួន៤ នឹងត្រូវបានផ្តល់ដល់ស្ថានីយ៍ពន្លត់អគ្គិភ័យ ដែលក្នុងនោះមានរាជធានីភ្នំពេញចំនួន២គ្រឿង ខេត្តកណ្តាលចំនួន១គ្រឿង និងខេត្តព្រះសីហនុចំនួន១គ្រឿង ដើម្បីជួយសម្រួលដល់ការសង្គ្រោះបន្ទាន់ និងការថែទាំឱ្យបានលឿន ក្នុងករណីអគ្គិភ័យ។ គំនិតផ្តួចផ្តើមនេះនឹងផ្តល់អត្ថប្រយោជន៍ដល់ប្រជាជនប្រមាណ ៤,១៤ លាននាក់ ជាមួយការលើកកម្ពស់នូវប្រតិបត្តិការជួយសង្គ្រោះផ្នែកអគ្គិភ័យ និងបង្កើនសុវត្ថិភាពសាធារណៈ។

**២. គម្រោងបំពាក់បរិក្ខារពេទ្យនៅមន្ទីរពេទ្យបង្អែកបរកែវ ក្នុងខេត្តរតនគិរី (ថវិកាចំនួន ៦៣,២៨០ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ មន្ទីរពេទ្យបង្អែកបរកែវ

ជំនួយនេះនឹងត្រូវបានប្រើប្រាស់ដើម្បីបំពាក់ម៉ាស៊ីនថតកាំរស្មីអ៊ិច ម៉ាស៊ីនចាប់ចង្វាក់បេះដូង និងម៉ាស៊ីនភ្លើងថ្មី នៅមន្ទីរពេទ្យបង្អែកបរកែវ។ ចាប់តាំងពីម៉ាស៊ីនថតកាំរស្មីអ៊ិចបានខូចក្នុងឆ្នាំ២០២១ អ្នកជំងឺដែលត្រូវការថតរូបភាពកាំរស្មីអ៊ិចត្រូវធ្វើដំណើរចម្ងាយ ៣០គីឡូម៉ែត្រ ទៅកាន់មន្ទីរពេទ្យខេត្ត ដោយចំណាយទាំងថ្លៃធ្វើដំណើរខ្ពស់ និងពន្យារពេលក្នុងការធ្វើរោគវិនិច្ឆ័យជំងឺ។ បន្ថែមពីនេះ ការដាច់ភ្លើងញឹកញាប់ ជាពិសេសក្នុងរដូវវស្សា កាន់តែរាំងស្ទះដល់ការព្យាបាល។ ដោយសារអគារព្យាបាលជំងឺទូទៅខ្វះម៉ាស៊ីនភ្លើង គ្រូពេទ្យត្រូវប្រើប្រាស់ពិលដើម្បីធ្វើការងារ។ មន្ទីរពេទ្យក៏ខ្វះនូវម៉ាស៊ីនចាប់ចង្វាក់បេះដូងផងដែរ ដែលចាំបាច់ក្នុងការរកឃើញសញ្ញាដំបូងនៃជំងឺបេះដូង។ តាមរយៈការបំពាក់ម៉ាស៊ីនថតកាំរស្មីអ៊ិច ម៉ាស៊ីនចាប់ចង្វាក់បេះដូង និងម៉ាស៊ីនភ្លើងថ្មី មន្ទីរពេទ្យនឹងអាចផ្តល់ការធ្វើរោគវិនិច្ឆ័យបានលឿន និងត្រឹមត្រូវជាងមុន ដែលលើកកម្ពស់ការថែទាំអ្នកជំងឺប្រមាណ ៩,៥០០នាក់ ជារៀងរាល់ឆ្នាំ និងកាត់បន្ថយបន្ទុកផ្នែកហិរញ្ញវត្ថុលើសហគមន៍ជនបទ។

គម្រោងគូសាណូហ្គោណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្តាបនាប្រទេសឡើងវិញ នៅតាមកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង/ឬ ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង ៧២លាន ដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូហ្គោណិ ចំនួន ៧០៦គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំកម្ពុជា*

*ទូរស័ព្ទ៖ ០២៣-២១៧-១៦១*

*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*

*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង**
**សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ**
**ថ្ងៃ០៩ ខែតុលា ឆ្នាំ២០២៥**

សូមគោរព

- **ឧត្តមសេនីយ៍ឯក នេត វន្ថា** ប្រធាននាយកដ្ឋាននគរបាលបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ នៃក្រសួងមហាផ្ទៃ
- **លោក ជា សានិត** ប្រធានមន្ទីរសុខាភិបាលខេត្តរតនគីរី
- **លោក ប៉ាន់ សារ៉ន** ប្រធានមន្ទីរពេទ្យបង្អែកបរកែវខេត្តរតនគីរី
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

អរុណសួស្តី និងសូមស្វាគមន៍មកកាន់ស្ថានទូតជប៉ុន។ ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាថ្ងៃនេះ លើកិច្ចសន្យាផ្តល់ជំនួយឥតសំណង ដែលនឹងត្រូវបានអនុវត្តក្រោម ជំនួយឥតសំណងគូសាណ្សូណិសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ។

មុននឹងចាប់ផ្តើមសុន្ទរកថា ខ្ញុំសូមបួងសួងសូមឲ្យវិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតក្នុងជម្លោះព្រំដែនរវាងកម្ពុជានិងថៃនាពេលថ្មីៗនេះបានទៅកាន់សុគតិភព និងសូមសម្តែងនូវក្តីអាណិតអាសូរជាពន់ពេកចំពោះអ្នកដែលទទួលរងគ្រោះទាំងអស់ផងដែរ។ រដ្ឋាភិបាលជប៉ុនសូមចូលរួមសាទរចំពោះកិច្ចព្រមព្រៀងស្តីពីបទឈប់បាញ់បន្ទាន់ និងឥតលក្ខខណ្ឌ កាលពីថ្ងៃទី២៨ ខែកក្កដាកន្លងទៅ និងកិច្ចប្រជុំជាបន្តបន្ទាប់ ដើម្បីជំរុញកិច្ចព្រមព្រៀងបទឈប់បាញ់ ហើយយើងសង្ឃឹមថាបញ្ហានេះនឹងត្រូវបានដោះស្រាយឲ្យបានឆាប់តាមដែលអាចធ្វើទៅបានតាមរយៈការសន្ទនាដោយសន្តិវិធី។ យើងនឹងបន្តជួយគាំទ្រទាំងជនរងគ្រោះនៃជម្លោះព្រំដែន និងការស្តាបនាតំបន់ព្រំដែនឡើងវិញ ហើយយើងបានផ្តល់ជូននូវជំនួយសង្គ្រោះបន្ទាន់ចំនួន ១,៨លានដុល្លារអាមេរិករួចមកហើយ ដើម្បីគាំទ្រដល់ប្រជាជនក្នុងតំបន់រងគ្រោះ។

ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបាននិងកំពុងផ្តល់ជំនួយឥតសំណងគូសាណ្សូណិនៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលកំពុងអនុវត្តគម្រោងរបស់ពួកគាត់។ គូសាណ្សូណិ មានន័យថា "ឫសស្មៅ" ក្នុងភាសាជប៉ុន។ ក្នុងរយៈពេលជាង៣០ឆ្នាំកន្លងមកនេះ ស្ថានទូតជប៉ុន បានអនុវត្តជាង ៧០០គម្រោង នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍ជំនួយឥតសំណងគូសាណ្សូណិ។ យើងមានសេចក្តីសោមនស្ស

រីករាយដែលគម្រោងទាំងនេះ បានចូលរួមចំណែកដោយផ្ទាល់ក្នុងការលើកកម្ពស់គុណភាពជីវភាពរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ខ្ញុំសូមណែនាំគម្រោង ដែលយើងបានចុះហត្ថលេខានាថ្ងៃនេះ។

សម្រាប់គម្រោងទី១ ដែលអនុវត្តដោយនាយកដ្ឋាននគរបាលបង្ការពន្លត់អគ្គិភ័យ និងសង្គ្រោះ នៃក្រសួងមហាផ្ទៃ រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាចំនួន ១២០,៣០៨ ដុល្លារអាមេរិក (មួយរយម្ភៃពាន់បីរយប្រាំបីដុល្លារអាមេរិក) ដើម្បីប្រើប្រាស់ឡើងវិញនូវរថយន្តសង្គ្រោះបន្ទាន់ដែលនឹងនាំចូលពីប្រទេសជប៉ុន។ យើងរំពឹងថា រថយន្តសង្គ្រោះបន្ទាន់ចំនួន៤គ្រឿង ដែលប្រើប្រាស់ឡើងវិញនេះ នឹងធ្វើឱ្យក្រុមគ្រូពេទ្យនៅស្ថានីយ៍ពន្លត់អគ្គិភ័យអាចផ្តល់ការថែទាំសង្គ្រោះបន្ទាន់យ៉ាងឆាប់រហ័សក្នុងករណីមានអគ្គិភ័យ។ ខ្ញុំសង្ឃឹមថា ជំនួយនេះនឹងជួយការពារអាយុជីវិតប្រជាជនជាង ៤,១ លាននាក់នៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ។

សម្រាប់គម្រោងទី២ ដែលអនុវត្តដោយមន្ទីរពេទ្យបង្អែកបរកែវ ក្នុងខេត្តរតនគីរី រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាចំនួន ៦៣,២៨០ ដុល្លារអាមេរិក (ហុកសិបបីពាន់ពីររយប៉ែតសិបដុល្លារអាមេរិក) ដើម្បីជាជំនួយសម្រាប់ការបំពាក់បរិក្ខារពេទ្យនៅមន្ទីរពេទ្យបង្អែកបរកែវ។ គ្រឿងបរិក្ខារថ្មីនេះ ត្រូវបានរំពឹងថា នឹងជួយក្នុងការធ្វើរោគវិនិច្ឆ័យដំបូង និងព្យាបាលបានឆាប់រហ័សសម្រាប់ជនរងគ្រោះក្នុងគ្រោះថ្នាក់ និងអ្នកជំងឺដែលត្រូវការសង្គ្រោះបន្ទាន់។ ជាលទ្ធផលនៃគម្រោងនេះ យើងរំពឹងថាអ្នកជំងឺប្រមាណ ៩,៥០០នាក់ ក្នុងមួយឆ្នាំៗ នឹងទទួលបានការថែទាំវេជ្ជសាស្ត្រប្រកបដោយប្រសិទ្ធភាព និងបន្ធូរបន្ថយនូវបន្ទុកនានា។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលសង្កេតឃើញប្រទេសកម្ពុជាមានការអភិវឌ្ឍយ៉ាងឆាប់រហ័សនាពេលថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមនានា ដែលត្រូវដោះស្រាយ ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន។ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈគ្រោងការណ៍ជំនួយអភិវឌ្ឍន៍ផ្លូវការនានា រួមទាំង "គូសាណូណិ" ផងដែរ។

ជាចុងក្រោយ ខ្ញុំសូមជូនពរ លោក លោកស្រី ដែលមានវត្តមាននៅទីនេះ សូមមានសុខភាពល្អ សុភមង្គល និងសូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណច្រើនសម្រាប់ការយកចិត្តទុកដាក់ស្តាប់។